# ការណែនាំក្នុងការរៀបចំគម្រោងសង្ខេប
## នៃគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា

លោក-លោកស្រីត្រូវបំពេញពត៌មាននៃគម្រោងសង្ខេប នៅក្នុងទំរង់បែបបទតាមគំរូដែលបានផ្សព្វផ្សាយ។ លោក-លោកស្រីអាចបំពេញពត៌មានតាមរយៈអក្សរកុំព្យូទ័រ ឬសរសេរដោយដៃ។

សូមលោក-លោកស្រីត្រូវយកចិត្តទុកដាក់ពិនិត្យមើលឡើងវិញ អំពីពត៌មានដែលបានបំពេញរួចតាមផ្នែកនីមួយៗ ។

ការរៀបចំគម្រោងសង្ខេបគឺជាដំណាក់កាលដំបូង សំរាប់ទទួលបានជំនួយគាំទ្ររបស់មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា។ លោក-លោកស្រីនឹងបន្តទៅដំណាក់កាលទី២ទៀត បើសិនលោក-លោកស្រីបំពេញនូវពត៌មានទាំងឡាយក្នុងគម្រោងសង្ខេបនេះបានត្រឹមត្រូវល្អ ហើយព័ត៌មានទាំងនោះឆ្លើយតបទៅនឹងការតម្រូវរបស់គំរោង។

## ពត៌មានលំអិត

សូមពិនិត្យឲ្យបានច្បាស់លាស់ថាលោក-លោកស្រីបានផ្ដល់ពត៌មានសំរាប់ទំនាក់ទំនងបានត្រឹមត្រូវ ដើម្បីឲ្យក្រុមការងារគ្រប់គ្រងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យាអាចទាក់ទងលោក-លោកស្រីបាន។

សូមផ្ដល់ពត៌មានប្រសិនបើសហគ្រាសគ្រប់គ្រងដោយស្ត្រីឬមានស្ត្រីជាម្ចាស់។ សហគ្រាសដែលមានអ្នកគ្រប់គ្រង ឬម្ចាស់ជាស្ត្រី នឹងត្រូវបានលើកទឹកចិត្តដោយគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា ប៉ុន្តែសហគ្រាសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ ត្រូវបានលើកយកមកធ្វើការសិក្សាសំរាប់ទទួលបានការគាំទ្រពីមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា។

សហគ្រាសដែលចាត់ទុកថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយអាចបន្តទៅដំណាក់កាលទី២ នៃគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា ត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាង ក្រោមនេះ ៖

- សហគ្រាសធុនតូច និងមធ្យមដែលបានចុះបញ្ជីនៅក្រសួង ឬមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពលនិងមានបុគ្គលិក/កម្មករតិចជាង១០០នាក់ ព្រមទាំងមានដើមទុនជាទ្រព្យសកម្មតិចជាង ៥០ម៉ឺន ដុល្លាអាមេរិក ។ ទុនជាទ្រព្យសកម្មនោះ គិតបញ្ចូលទាំងតម្លៃអាគារ គ្រឿងចក្រ គ្រឿងបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងទុនបង្វិល។
- ម្ចាស់សហគ្រាសត្រូវមានសញ្ជាតិកម្ពុជា ។
- ជាសហគ្រាសដែលបានដំណើរការអាជីវកម្មពាក់ព័ន្ធនឹងឧស្សាហកម្មកែច្នៃម្ហូបអាហារ និងភេសជ្ជៈ យ៉ាងតិច ២ ឆ្នាំ។
- ស្ម័គ្រចិត្តអនុវត្តតាមក្រមសីលធម៌សង្គមរបស់មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា ។

ហេតុដូចនេះ៖

- ពត៌មានស្តីពីសកម្មភាពជំនួញរបស់លោក-លោកស្រីត្រូវបង្ហាញថា លោក-លោកស្រីបានពាក់ព័ន្ធក្នុងវិស័យឧស្សាហកម្មកែច្នៃម្ហូបអាហារ និងភេសជ្ជៈអស់រយៈ ពេលយ៉ាងតិចបំផុត ២ឆ្នាំ ដើម្បីតំរូវតាមលក្ខណៈសម្បត្តិសំរាប់ការគាំទ្ររបស់គម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេក-វិទ្យា។ លោក-លោកស្រីត្រូវផ្តល់ពត៌មានអំពីផលិតផលដែលសហគ្រាសលោក-លោកស្រីផលិត។
- យើងត្រូវការពត៌មានពីចំនួនបុគ្គលិក ឬ កម្មករបំរើការងារក្នុងសហគ្រាសរបស់លោក-លោកស្រី ហើយនិងទុនជាទ្រព្យសកម្ម របស់លោក-លោកស្រី សំរាប់កំណត់ថាតើសហគ្រាសរបស់លោក-លោកស្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សំរាប់ទទួលការគាំទ្រពីគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យាឬទេ?
- លោក លោកស្រីត្រូវបញ្ជាក់ឲ្យច្បាស់ថាអាជីវកម្មរបស់លោក-លោកស្រី ត្រូវបានចុះបញ្ជីរួច ហើយសូមផ្តល់នូវឯកសារចាំបាច់ភ្ជាប់មកជាមួយ។
- លោក-លោកស្រីត្រូវបញ្ជាក់ថា គម្រោងអាជីវកម្មរបស់លោក-លោកស្រីមិនពាក់ព័ន្ធនឹងគ្រឿងស្រវឹង ឬ ថ្នាំជក់ ពីព្រោះគម្រោងនេះមិនមានការគាំទ្រពីគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យាទេ។

## គម្រោងដែលអាចទទួលការគាំទ្រពីមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា៖

គម្រោងកែលំអអាជីវកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចបន្តទៅដំណាក់កាលទី២បានត្រូវឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះ៖

- ផ្តោតលើការកែលំអអនាម័យឲ្យអនុលោមតាមស្តង់ដារ ហើយពាក់ព័ន្ធនឹងក្បួនអនុវត្តន៍ និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ។ មូលនិធិរបស់គំរោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យានឹងមិនត្រូវបានយកមកប្រើប្រាស់សំរាប់ការសិក្សាស្រាវជ្រាវទីផ្សារ និងទស្សនៈកិច្ចសិក្សាទេ។
- ការវិនិយោគលើផ្នែកបច្ចេកវិទ្យា ក្នុងគោលបំណងកែលំអប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ (រួមមានគ្រឿងបរិក្ខារ គ្រឿងចក្រ ការបណ្តុះបណ្តាល ការកែលំអការគ្រប់គ្រង ហើយនិងការកែលំអដើម្បីទទួលវិញ្ញាបនប័ត្រ ឬ ភាពអនុលោមតាមស្តង់ដារអន្តរជាតិលើសុវត្ថិភាពចំណីអាហារ)។
- គម្រោងដែលជួយបង្កើនផលិតភាព ការបង្កើតអោយមានការកែច្នៃសមស្របមួយ និងមានសក្តានុពលក្នុងការបង្កើននូវការលក់ និងប្រាក់ចំណេញ។
- ជាគម្រោងបង្ហាញគំរូល្អ ដែលអាចឲ្យសហគ្រាសដូចគ្នាក្នុងប្រទេសយកគំរូតាម និងជាគម្រោងមិនពាក់ព័ន្ធនឹងគ្រឿងស្រវឹង និងថ្នាំជក់។

## ផែនការកែលំអសំរាប់អាជីវកម្ម

ផ្នែកនេះ លោក-លោកស្រីត្រូវរៀបរាប់ឲ្យច្បាស់អំពីគម្រោងកែលំអអាជីវកម្មដែលលោក-លោកស្រីបានលើកជាផែនការ។ លោក-លោកស្រីត្រូវបញ្ជាក់ឲ្យច្បាស់ ថាតើគម្រោងពាក់ព័ន្ធនឹងបង្កើតផលិតផលថ្មី ឬក៏ពង្រីកផលិតកម្មដែលមានស្រាប់ ។

គម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចរួមមាន ប្រព័ន្ធ ឬក៏បច្ចេកវិទ្យាថ្មីៗ ដើម្បីកែលំអការកែច្នៃម្ហូបអាហារ និងភេសជ្ជៈឲ្យមានស្តង់ដារអនាម័យ ការទិញគ្រឿងបរិក្ខារថ្មីដើម្បីកែលំអស្តង់ដារ និងកែលំអអាជីវកម្ម បំពាក់បរិក្ខាសំរាប់ធ្វើតេស្តអនាម័យ ការគ្រប់គ្រងនិងបណ្តុះបណ្តាលបុគ្គលិកដើម្បីកែលំអស្តង់ដារអនាម័យ និងដើម្បីទទួលបានវិញ្ញាបនប័ត្រស្តង់ដារ ឬភាពអនុលោមស្តង់ដារ ឬសកម្មភាពស្រដៀងគ្នាផ្សេងៗទៀត ។

មូលនិធិនៃគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា មិនត្រូវបានផ្តល់ឲ្យសំរាប់ការសាងសង់ ឬការពង្រីកអាគារថ្មី ក្នុងគោលដៅបង្កើនផលិតកម្ម ឬការផលិតថាមពល។ គម្រោងដែលលោកលោកស្រីកំពុងធ្វើផែនការ ត្រូវបង្ហាញពីលទ្ធផលក្នុងការកែលំអប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ។ មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យាមិនផ្តល់មូលនិធិឲ្យគម្រោងស្រាវជ្រាវទីផ្សារ ឬគម្រោងទស្សនៈកិច្ចសិក្សាទេ។

នេះគឺជាផ្នែកមួយដ៏សំខាន់នៃការរៀបចំគម្រោងសង្ខេប ហើយលោក-លោកស្រីត្រូវយល់ដឹងឲ្យបានច្បាស់ពីគម្រោងដែលលោក-លោកស្រីកំពុងធ្វើផែនការ។

## តើគម្រោងនឹងសំរេចបានលទ្ធផលដែលរំពឹងទុកពីគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យាយ៉ាងដូចម្តេច?

វាមានសារៈសំខាន់ណាស់ក្នុងការរៀបរាប់ ថាតើគម្រោងដែលលោក-លោកស្រីកំពុងធ្វើផែនការ នឹងជួយកែលំអអាជីវកម្មរបស់លោក-លោកស្រីយ៉ាងដូចម្តេច ហើយឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកពីគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យាយ៉ាងដូចម្តេច។

លោក-លោកស្រីត្រូវរៀបរាប់ឲ្យបានច្បាស់ពីការកែលំអដែលរំពឹងទុក និងបង្ហាញថាលោក-លោកស្រីយល់ច្បាស់ថាវាសមស្របតាមគោលបំណងរបស់មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា។

លក្ខណៈវិនិច្ឆ័យរបស់គម្រោងដែលបានចែងនៅទំព័រដំបូងផ្តល់ជាការណែនាំ នូវអ្វីដែលជាលទ្ធផលរំពឹងទុកពីគម្រោង ប៉ុន្តែសូមកុំចម្លងលក្ខណៈវិនិច្ឆ័យទាំងនេះ។ ឧទាហរណ៍ៈ បើសិនជាលោក-លោកស្រីកំពុងធ្វើផែនការគ្រប់គ្រង និងបណ្តុះបណ្តាលដល់បុគ្គលិក លោក-លោកស្រីត្រូវការពន្យល់ពីមូលហេតុនៃការចាំបាច់របស់ផែនការនេះ ហើយថាតើលទ្ធផលរបស់គម្រោង មានការពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ យ៉ាងដូចម្តេចដែរ។

លោក-លោកស្រីមានឱកាសកាន់តែច្រើន ពីការគាំទ្ររបស់គម្រោងមូលនិធិអភិឌ្ឍន៍បច្ចេក-វិទ្យា បើសិនលោក-លោកស្រីអាចបង្ហាញពីផែនការកែលំអអាជីវកម្មបានច្បាស់លាស់ ដែលនឹងសំរេចបានលទ្ធផលត្រឹមត្រូវតាមគោលបំណងរបស់គម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា។

## សេចក្តីប្រកាស

សូមបញ្ជាក់ថា លោក-លោកស្រីត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសក្នុងគម្រោងសង្ខេបនេះ។ គម្រោងសង្ខេបដែលមិនបានចុះហត្ថលេខា នឹងមិនអាចទទួលយកបាន។
សូមភ្ជាប់មកជាមួយនូវឯកសារថតចម្លងចាំបាច់ដែលបានចែងក្នុងគម្រោងសង្ខេប។ ប្រសិនបើមិនបានភ្ជាប់នូវឯកសារទាំងនោះ គម្រោងសង្ខេបនឹងមិនត្រូវបានទទួលយកទេ។

## ឯកសារភ្ជាប់៖ ក្រមសីលធម៌សង្គម

បើសិនជាលោក-លោកស្រីយល់ព្រមអនុវត្តតាមក្រមសីលធម៌សង្គម ដែលជាការតម្រូវរបស់គម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា លោក-លោកស្រីត្រូវចុះហត្ថលេខាលើក្រមសីលធម៌នេះ។ គម្រោងសង្ខេបណាដែលមិនបានចុះហត្ថលេខានឹងត្រូវបាន បដិសេធចោល ។

សូមពិនិត្យមើលឡើងវិញនូវការតម្រូវទាំងអស់របស់ក្រមសីលធម៌មុននឹងចុះហត្ថលេខា។ ប្រសិនបើគម្រោងកែលំអរបស់លោក លោកស្រីត្រូវបានជ្រើសរើសឲ្យចូលដំណាក់កាលទី ២ នោះតំណាងគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យានឹងចុះទៅទីតាំងអាជីវកម្មរបស់លោក លោកស្រី ដើម្បីពិនិត្យមើល ថាតើក្រមសីលធម៌អាចបំពេញបានតាមតំរូវការឬទេ?

## កន្លែងទទួលគម្រោងសង្ខេប

គម្រោងសង្ខេបដែលបានបំពេញរួចរាល់អាចផ្ញើតាមអ៊ីម៉ែល ទូរសារ ឬផ្ញើទៅអាស័យដ្ឋានដូចខាងក្រោម លោក-លោកស្រីនឹងទទួលបានបង្កាន់បញ្ជាក់។

អាស័យដ្ឋាន: #៤៥ មហាវិថីព្រះនរោត្តម សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ
អ៊ីម៉ែល: tdf.project@yahoo.com
ទូរស័ព្ទ: ០២៣ ២២២ ៥០៤

សូមបញ្ជាក់ថា គម្រោងស្នើសុំ ដែលមិនបានទទួលតាមកាលបរិច្ឆេទដែលបានកំណត់ ត្រូវចាត់ទុកជាអាសារបង់។